# <u>កិច្ចការបញ្ចប់មេរៀនទី៤២-សញ្ញាសួរ " ? " ដល់ មេរៀនទី៤៣ សិប្បកម្មថ្មកែវ</u>

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

> សិប្បកម្មជាកន្លែងផលិតកម្មធុនតូច ។ សិប្បកម្មចម្លាក់ថ្មកែវនៅខេត្តពោធិ៍សាត់ មានកេរ្តិ៍ឈ្មោះល្បីល្បាញតាំងពីយូរលង់ណាស់មកហើយ។ អ្នកទេសចរដែលបានទៅកម្សាន្តនៅទីនោះ តែងតែចាប់អារម្មណ៍ និងស្ងើចសរសើរចំពោះស្នាដៃថដ៏មានក្បូរក្បាច់រចនាល្អផូរផង់ ជាមរតកដូនតាយើង ។
>
> នៅប្រទេសកម្ពុជា ថ្មកែវភាគច្រើនមាននៅភ្នំតែសែ ភ្នំយ៉ន និងភ្នំស្តង់ ក្នុងស្រុកភ្នំក្រវាញ នៃទឹកដីខេត្តពោធិ៍សាត ។ ថ្មកែវ ជាប្រភេទថ្មធម្មជាតិម្យ៉ាងដែលមានពណ៌ចម្រុះភ្លឺរលោង ធាចយកមកឆ្លាក់ធ្វើជារូបសំណាកផ្សេងៗ ថ្មកែវ ជាធនធានធម្មជាតិមានសារៈសំខាន់ចំពោះប្រទេសកម្ពុជាយើង។
>
> សិប្បកម្មថ្មកែវ បានលើកស្ទួយកម្រិតជីវភាពប្រជាជនក្នុងស្រុកភ្នំក្រវាញ នៃខេត្តពោធិ៍សាត់ឱ្យកាន់តែ សម្បូរធូរធារ ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើអត្ថបទនេះមានចំណងជើងអ្វី ?

☐ ក. សិប្បកម្មថ្មកែវ　　☐ ខ. ប្រវត្តិខេត្តពោធិ៍សាត់

☐ គ. រមណីយដ្ឋាន　　☐ ឃ. ជាងចម្លាក់

២. តើនៅប្រទេសកម្ពុជា ថ្មកែវភាគច្រើនមាននៅក្នុងខេត្តណា ?

☐ ក. ខេត្តប៉ៃលិន　　☐ ខ. ខេត្តកំពង់ស្ពឺ

☐ គ. ខេត្តមណ្ឌលគិរី　　☐ ឃ. ខេត្តពោធិ៍សាត់

៣. តើថ្មកែវមានពណ៌ដូចម្តេច ?

☐ ក. ពណ៌ភ្លឺរលោង　　☐ ខ. ពណ៌ភ្លឺថ្លា

☐ គ. ពណ៌ចម្រុះភ្លឺរលោង　　☐ ឃ. ពណ៌ខៀវភ្លឺ

LIVEWORKSHEETS

៤. តើគេយកថ្មកែវមកធ្វើអ្វី ?

- [ ] ក. ធ្វើជារបស់ប្រើប្រាស់
- [ ] ខ. ឆ្លាក់ធ្វើជារូបសំណាកផ្សេងៗ
- [ ] គ. ធ្វើជាថ្មសំលៀងកាំបិត
- [ ] ឃ. ធ្វើជាគ្រឿងអលង្ការ

៥. តើភ្នំតាសែ ភ្នំយ៉ន និងភ្នំស្តង់ ស្ថិតក្នុងស្រុកណា នៃខេត្តពោធិ៍សាត់ ?

- [ ] ក. ស្រុកក្រគរ
- [ ] ខ. ស្រុកភ្នំក្រវាញ
- [ ] គ. ស្រុកកណ្តៀវ
- [ ] ឃ. ស្រុកបាកាន

៦. ក្នុងចំណោមល្បះខាងក្រោម តើល្បះមួយណាដែលជាគំនិតសំខាន់របស់អត្ថបទ ?

- [ ] ក. ថ្មកែវជាប្រភេទថ្មធម្មជាតិម្យ៉ាងគ្មានតម្លៃ
- [ ] ខ. ថ្មកែវអាចយកមកឆ្លាក់ជារូបសំណាកផ្សេងៗ
- [ ] គ. ចម្លាក់ថ្មកែវ ធ្វើឱ្យជីវភាពប្រជាជនសម្បូរធូរធារ ។
- [ ] ឃ. ថ្មធម្មជាតិមានសារប្រយោជន៍ ។

៧. ចូរគូសភ្ជាប់ពាក្យដែលជានាម គុណនាម និងកិរិយាសព្ទឱ្យបានត្រឹមត្រូវ ។

| ក | ខ |
|---|---|
| | តូច |
| នាម | សក្ការៈ |
| គុណនាម | ចម្លាក់ |
| កិរិយា | សើច |
| | ថ្ម |

៨. ចូរគូសភ្ជាប់ពីតារាង " ក " ទៅ " ខ " ឱ្យបានជាល្បះត្រឹមត្រូវ ។

| ក | ខ |
|---|---|
| ១. ថ្មកែវជាប្រភេទថ្មធម្មជាតិមានតម្លៃ.......... | |
| ២. តើគេយកថ្មកែវមកឆ្លាក់ធ្វើអ្វី.................. | ? |
| ៣. តើសិប្បកម្មថ្មកែវជួយលើកស្ទួយជីវភាពប្រជាជនមែនឬទេ............ | ។ |
| ៤. តើថ្មកែវភាគច្រើនមាននៅឯណា............ | |

LIVEWORKSHEETS

➢ សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោម ។

➢ សិប្បកម្ម ( ន ) ...........................................................................................

➢ ធនធាន ( ន ) ...........................................................................................

➢ ធម្មជាតិ ( ន ).............................................................................................

២. ចូររៀបពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ឱ្យបានជាល្បះត្រឹមត្រូវ ។

ក.

| | | | | | |
|---|---|---|---|---|---|
| ធ្វើឱ្យ | វង្វេង | សុរា | ស្មារតី ។ | អ្នកសេព | តែងតែ |

...........................................................................................................

ខ.

| | | | | | |
|---|---|---|---|---|---|
| មាន | គ្រឿងស្រវឹង | សេព | ក្នុងគ្រួសារ ។ | អំពើហិង្សា | នាំឱ្យ |

...........................................................................................................

៣. ចូររកសទិសសព្ទនឹងពាក្យ " ជន " ។

➢ ជន (ន) ...........................................................................................

➢ ជន់ (កិ) ...........................................................................................

➢ ជន្ម (ន) ...........................................................................................

៤. តើគេប្រើសញ្ញាសួរ " ? " ដើម្បីអ្វី? គេដាក់សញ្ញាសួរនៅបន្ទាប់ពីពាក្យអ្វីខ្លះ ? ចូរបង្កើតល្បះសំណួរឱ្យបានបីល្បះ ។

ក/...........................................................................................

ក/...........................................................................................

ក/...........................................................................................

LIVEWORKSHEETS